# គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

## ការបង្រៀន «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ក្រោមកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា

ចាប់តាំងពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងខែមករាឆ្នាំ១៩៧៩មក កិច្ចខិតខំប្រឹងប្រែងក្នុងការបង្រៀនប្រវត្តិសាស្ត្រនៃរបបនេះដល់ប្រជាជនកម្ពុជា ជាពិសេសក្មេងជំនាន់ក្រោយ ត្រូវបានធ្វើឡើងតាមវិធីសាស្ត្រជាច្រើន រួមទាំងការបង្រៀននៅសាលាដែលមានលក្ខណៈជាការឃោសនានយោបាយដើម្បីទទួលបានការគាំទ្រពីសហគមន៍អន្តរជាតិ និងការនិយាយប្រាប់រឿងរ៉ាវដ៏ជូរចត់នេះពីសំណាក់ឪពុកម្តាយទៅកូនចៅរបស់ខ្លួន ។ តាមរយៈមធ្យោបាយបែបនេះ ការបង្រៀនប្រវត្តិសាស្ត្រត្រូវបានមើលឃើញថា មិនទាន់មានលក្ខណៈគ្រប់គ្រាន់ និងមិនអាចឋិតថេរបានយូរអង្វែងឡើយ ។

២៨ឆ្នាំក្រោយមក សៀវភៅសិក្សា «*ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)*» ថ្មីមួយ ត្រូវបានបោះពុម្ពជាលើកដំបូងក្នុងឆ្នាំ២០០៧ ។ សៀវភៅនេះ ត្រូវបានសរសេរឡើងដោយលោក ឌី ខាំបូលី អ្នកស្រាវជ្រាវខ្មែរមួយរូបដែលកំពុងបម្រើការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានជំនួយទ្រទ្រង់ហិរញ្ញវត្ថុពីសំណាក់អង្គការទេយ្យទានជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ និងវិទ្យាស្ថានសង្គមសេរី ។ លោក ឌី ខាំបូលី បានចំណាយពេលវេលាចំនួន៣ឆ្នាំ ដើម្បីសរសេរនិងបោះពុម្ពផ្សាយសៀវភៅនេះ ។ សៀវភៅប្រវត្តិសាស្ត្រនេះត្រូវបានត្រួតពិនិត្យ ដោយគណៈកម្មការត្រួតពិនិត្យរបស់ក្រសួង ហើយចុងបញ្ចប់ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ជាឯកសារជំនួយក្នុងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅថ្នាក់មធ្យមសិក្សានៅទូទាំងប្រទេសកម្ពុជា ។ រហូតមកដល់ថ្ងៃនេះ សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យចំនួន៣០០.០០០ក្បាល ត្រូវបានចែកជូនដល់សិស្សានុសិស្សនៅទូទាំងប្រទេសកម្ពុជាដោយឥតគិតថ្លៃ ។

ក្នុងឆ្នាំ២០០៩ ក្រោមការសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅណែនាំគ្រូបង្រៀន សម្រាប់លោកគ្រូអ្នកគ្រូប្រើប្រាស់ក្នុងការបង្រៀនសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ សៀវភៅនេះ ត្រូវបានរៀបចំឡើងយ៉ាងសំរិតសំរាំងសម្រាប់គ្រូប្រវត្តិសាស្ត្រ និងមានគោលបំណងឲ្យលោកគ្រូអ្នកគ្រូមានលទ្ធភាពក្នុងការបង្រៀនសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ឲ្យសមស្របតាមក្បួនខ្នាត និងគរុកោសល្យត្រឹមត្រូវ ។ លើសពីនេះទៀត សៀវភៅលំហាត់របស់សិស្សគឺកំពុងតែត្រូវបានបញ្ចប់ មុនពេលដែលសៀវភៅនេះត្រូវបញ្ជូនទៅបោះពុម្ព ដើម្បីជាជំនួយដល់សិស្សឲ្យមានការយល់ដឹងកាន់តែច្បាស់លាស់ទៅលើសៀវភៅប្រវត្តិសាស្ត្រ ។

ចាប់តាំងពីថ្ងៃទី២៩ ខែមិថុនា ដល់ថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៩ មជ្ឈមណ្ឌលឯកសារកម្ពុជា ក្រោមជំនួយទ្រទ្រង់ពីប្រទេសប៊ែលហ្ស៊ិក ប្រទេសស៊ុយអែត ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់សហរដ្ឋអាមេរិក វិទ្យាស្ថានសង្គមសេរី ប្រទេសដាណឺម៉ាក និងប្រទេសម្ចាស់ជំនួយមួយចំនួនទៀត បានបើកសិក្ខាសាលាមួយ ដើម្បីបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិចំនួន២៤រូបមកពីក្រសួងអប់រំ យុវជន និងកីឡា និង១៥រូបមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា លើវិធីសាស្ត្រនៃការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងលើប្រធានបទផ្សេងៗដែលជាប់ពាក់ព័ន្ធដូចជា អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅបណ្តាប្រទេសដទៃៗទៀត និងច្បាប់អន្តរជាតិ។អ្នកជំនាញជាតិនិងអន្តរជាតិ ត្រូវបានអញ្ជើញឲ្យមកចូលរួម និងជួយរៀបចំសិក្ខាសានេះ។ នៅចុងឆ្នាំ២០០៩ មជ្ឈមណ្ឌលឯកសារកម្ពុជា រួមជាមួយគ្រូបង្គោលថ្នាក់ជាតិចំនួន៣៩រូប បានរៀបចំវគ្គបណ្តុះបណ្តាលលើកទី២ ដែលធ្វើឲ្យគ្រូបង្គោលថ្នាក់ខេត្តចំនួន១៨០រូប បានទទួលការបណ្តុះបណ្តាលនេះដោយជោគជ័យ។

ជាលទ្ធផលសម្រាប់វគ្គបណ្តុះបណ្តាលលើកទី២ សិក្ខាសាលាស្តីពីការបង្កើនសមត្ថភាពឲ្យកាន់តែប្រសើរឡើង នឹងត្រូវប្រារព្ធធ្វើឡើងរយៈពេល៣ថ្ងៃនៅខេត្តសៀមរាប។ គ្រូបង្គោលថ្នាក់ខេត្តទាំងអស់នឹងត្រូវចូលរួមក្នុងវគ្គសិក្ខាសាលានេះ ដើម្បីទទួលបានព័ត៌មាននិងចំណេះដឹងច្រើនបន្ថែមទៀតស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ មុនពេលចុះទៅបង្រៀនដល់គ្រូប្រវត្តិសាស្ត្រនៅថ្នាក់មូលដ្ឋានចំនួន១.៦២៧នាក់។ វគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋានលើកដំបូងនេះ នឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី៩ ដល់ថ្ងៃទី១១ ខែមេសា នៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាល និងវិក្រិត្យការខេត្ត ដែលរួមមាន ខេត្តកំពត ខេត្តព្រះសីហនុ ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ។ វគ្គបណ្តុះបណ្តាលនេះ នឹងមានការអញ្ជើញចូលរួមពីលោកគ្រូអ្នកគ្រូមកពីខេត្តកំពត កែប ព្រះសីហនុ កោះកុង ក្រចេះ មណ្ឌលគិរី រតនគិរី ព្រះវិហារ និងស្ទឹងត្រែង។

ខាងក្រោមនេះ គឺជាកម្មវិធីសម្រាប់វគ្គសិក្ខាសាលានៅខេត្តសៀមរាបៈ

## កម្មវិធីសម្រាប់ពិធីបើកវគ្គនៅខេត្តសៀមរាប គោជនីយដ្ឋាន អង្គរម៉ុងឌីយ៉ាល់ ២៨ មិនា ២០១០

### ថ្ងៃទី១ ៖ ថ្ងៃសៅរ៍ ទី២៧ ខែមិនា ឆ្នាំ២០១០ ៖ ដំណើរមកដល់ក្រុងសៀមរាប

០៨ៈ០០-១២ៈ០០ ការធ្វើដំណើរ និងការចុះឈ្មោះចូលកន្លែងស្នាក់នៅ។

១២ៈ០០-០២ៈ០០ អាហារថ្ងៃត្រង់

០៧:០០-០៩:០០ ការរៀបចំ (ត្រួតពិនិត្យទីកន្លែង និងសម្ភារៈផ្សេងៗសម្រាប់វគ្គសិក្ខាសាលា) (សម្រាប់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា)

## ថ្ងៃទី២ : ថ្ងៃអាទិត្យ ទី២៨ ខែមិនា ឆ្នាំ២០១០ : ពិធីបើកវគ្គនៅសណ្ឋាគារអង្គរម៉ុងឌីយ៉ាល់

០៨:០០-០៨:៣០ ការចុះបញ្ជីវត្តមាន និង ត្រៀមខ្លួនដើម្បីទទួលការអញ្ជើញមកដល់របស់គណៈអធិបតី ។

០៨:៣០-១០:០០ **កម្មវិធីបើកសិក្ខាសាលា**

- ការអញ្ជើញមកដល់របស់ លោកជំទាវ **ទន់ សាអ៊ីម** អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា ។
- ពិធីគោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា ។
- មតិស្វាគមន៍ចំពោះគណៈអធិបតី អ្នកចូលរួម និងភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ -**លោក វ៉ាន់ថាន់ ពៅដារ៉ា** នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា ។
- សុន្ទរកថារបស់ លោកជំទាវ **ទន់ សាអ៊ីម** អនុរដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា និងការប្រកាសបើកវគ្គបណ្តុះបណ្តាលគ្រូថ្នាក់មូលដ្ឋាន ។
- ពិធីចែកវិញ្ញាបនបត្រដល់គ្រូបង្គោលថ្នាក់ខេត្តចំនួន១៨០រូប ។
- ការអញ្ជើញនិវត្តន៍របស់លោកជំទាវ និងភ្ញៀវកិត្តិយស ។

១០:១៥-១០:៣០ សម្រាក និងពិសារអាហារសម្រន់

១០:៣០-១១:៣០ ការចោទប្រកាន់នៅក្នុងសំណុំរឿងលេខ ០០២ ដោយលោកសហព្រះរាជអាជ្ញាអន្តរជាតិ **អាន់ឌ្រូ ធី ខាលលៃ, អ្នកបកប្រែ : លោក ជី ទេរិទ្ធ**

១១:៣០-១២:៣០ **វិធីសាស្ត្រក្នុងការស្រាវជ្រាវឯកសារ - លោក ឆាំង យុ និងលោកសាស្ត្រាចារ្យ សំបូរ ម៉ាណ្ណារ៉ា**

- គោលបំណងនៃការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ
- ឯកសារតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា
- ឯកសារប្រវត្តិសាស្ត្រ : (ឯកសារដើម និង ឯកសារបន្ទាប់បន្សំ)

១២:៣០-១:៣០ អាហារថ្ងៃត្រង់ (បូហ្វេនៅហ្គឹងកន្លែង)

០១:៣០-០៣:០០ **វិធីសាស្ត្រក្នុងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ - លោក គ្រីស ឌៀរីង**

**អ្នកបកប្រែ ៖ លោក អេង កុកថាយ**

១. ពិនិត្យមើលទៅលើការរៀបចំសៀវភៅណែនាំសម្រាប់គ្រូបង្រៀន និង សៀវភៅលំហាត់សម្រាប់សិស្ស ។

២. បទបង្ហាញ ៖ មេរៀនគំរូ

០៣:០០-០៣:១៥ សម្រាក និង ពិសារអាហារសម្រន់

០៣:១៥-០៥:០០ ណែនាំក្រុមសម្រាប់ការបែងចែកក្រុម និងខេត្តទាំងបួន ៖ ខេត្តកំពត (បូកនិងខេត្តកែប, ខេត្តព្រះសីហនុ (បូកនិងខេត្តកោះកុង), ខេត្តស្ទឹងត្រែង (បូកនិងខេត្តព្រះវិហារ និងរតនៈគិរី), និងខេត្តក្រចេះ (បូកនិងខេត្តមណ្ឌលគិរី)

**ដោយលោក ផេង ពង្សរ៉ាស៊ី**

- បែងចែកក្រុមទៅតាមខេត្តនីមួយៗ
- ពិនិត្យមើលលើការរំពឹងទុករបស់គ្រូបង្គោលថ្នាក់មូលដ្ឋាន ថ្នាក់ខេត្ត និង ថ្នាក់ជាតិៈ តួនាទី និងការទទួលខុសត្រូវ ។
- ពិភាក្សាទៅលើសំណួរទាំងឡាយដែលសិក្ខាកាមអាចមានចំពោះការបែងចែកក្រុម ។
- ពិភាក្សាអំពីដំណើរទស្សនកិច្ចទៅកាន់ប្រាសាទនានានៅថ្ងៃបន្ទាប់ ។

០៥:០០-៦:០០ ពិភាក្សាអំពីល្ខោននិយាយរឿង "ទម្លាយភាពស្ងប់ស្ងាត់"

៦:០០ អាហារពេលល្ងាច (បូហ្វេនៅហ្វឹងកន្ធែង)

## ថ្ងៃទី៣ ៖ ថ្ងៃច័ន្ទ ទី២៩ ខែមិនា ឆ្នាំ២០១០ ៖ ដំណើរកំសាន្ត

០៨:០០-០៨:៣០ ជួបជុំគ្នានៅ**សណ្ឋាគារអង្គរម៉ុងឌីយ៉ាល់** ដើម្បីចេញដំណើរ (ឡានក្រុង)

០៨:៣០-១២:០០ ដំណើរទៅកាន់ប្រាសាទនានាក្នុងបរិវេណអង្គរ ។

- បន្ទាយស្រី
- បន្ទាយសំរែ
- បន្ទាយក្តី
- តាព្រហ្ម

១២:០០-០១:០០ ពិសារអាហារថ្ងៃត្រង់ (បាយកញ្ចប់)

០១:០០-០៦:០០ ចេញដំណើរទៅកាន់ប្រាសាទ

- តាកែវ

- បាយ័ន
- អង្គរវត្ត
- បាក់ខែង

**ថ្ងៃច័ន្ទ ទី៣០ ខែមិនា ឆ្នាំ២០១០ ៖ ដំណើរវិលត្រឡប់វិញ**

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក វ៉ាន់ថាន់ ពោធិដារ៉ា
ទូរស័ព្ទលេខ ០១២ ៨៤៦ ៥២៦
អ៊ីម៉ែល truthpdara@dccam.org